រក្សាសិទ្ធិ © ពត៌មាន :
© ២០០៩ Project WorldReach © ២០០៩ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

## បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :

**Project WorldReach PWR ™**

474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

035KH01A-01

# អំណាចរបស់ព្រះគម្ពីរ



## កូនស្បៃរំភៅសំរាប់បង្ហាត់បង្រៀនគ្រួគង្វាល

## ៣៥

## បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

**T&M ™**




**កំណត់ចំណាំ :**



*© Project WorldReach © SEAN*

**កំណត់ចំណាំ :**






© Project WorldReach © SEAN






## កិច្ចការដែលត្រូវអនុវត្ត

- បង្រៀនពួកសមាជិក អោយចេះបែងចែកអំណាចទាំងបីក៏រឹត សំរាប់ជីវិតជាគ្រីស្តជន ដោយបញ្ជាក់ថា យើងត្រូវតែប្រតិបត្តិតាមសេចក្តីបង្គាប់របស់ព្រះអម្ចាស់ជានិច្ច ។
- បើសិនជាមនុស្សខ្លះក្នុងក្រុមជំនុំចង់ប្រកាន់យកប្រពៃណី ឬទំនៀមទំលាប់ដែលធ្វើអោយរាំងស្ទះដល់ការស្តាប់បង្គាប់ព្រះគ្រីស្ត សូមកែតម្រូវកិច្ចការនេះ ។
- សូមសរសេរសេចក្តីបង្គាប់ខ្លះរបស់ព្រះគ្រីស្ត ដែលក្រុមជំនុំរបស់អ្នកត្រូវប្រតិបត្តិកាន់តែខ្លាំងឡើងៗ :

_____

_____

_____

_____

_____

_____

- សូមរៀនសាឡើងវិញអំពី «របៀបសិក្សាព្រះគម្ពីរ» (កូនសៀវភៅ ទី ១៤ របស់ក៏រឹត ទី ១) ។

© Project WorldReach © SEAN






៦- ត្រូវអោយពួកអ្នកចាស់ទុំថែរក្សាហ្វូងចៀម :

---

សូមអាន កិច្ចការ ២០:២៨ និង ១ ពេត្រុស ៥:១-៤ ដើម្បីអាចដឹងថា សកម្មភាពនេះជាអ្វី ។

៧- អធិស្ឋានសំរាប់អ្នកជំងឺ :

---

សូមអាន យ៉ាកុប ៥:១៤ ដើម្បីអាចដឹងថា សកម្មភាពនេះជាអ្វី ។

៨- ធ្វើពិធីកាច់នំបុ័ងនៅតាមផ្ទះអ្នកជឿ :

---

សូមអាន កិច្ចការ ២:៤៦ ដើម្បីអាចដឹងថា សកម្មភាពនេះជាអ្វី ។

ទូលសូមអោយព្រះវិញ្ញាណព្រះជាម្ចាស់ជីកនាំអ្នក ពេលអ្នកសិក្សាមេរៀននេះ ដើម្បីអោយអ្នកអាចបកស្រាយព្រះបន្ទូលព្រះជាម្ចាស់បានត្រឹមត្រូវ ។

ជួនកាល ក្នុងចំណោមគ្រូគង្វាលមានការច្របូកច្របល់ ។ គ្រូគង្វាលមួយនិយាយបែបនេះ គ្រូគង្វាលផ្សេងទៀតនិយាយបែបផ្សេង ។

ដើម្បីអោយយើងចេះតែយល់ ហើយដើម្បីឱ្យយើងអាចប្រតិបត្តិតាមតែព្រះគ្រីស្ត យើងត្រូវរៀនពីសេចក្តីបង្គាប់របស់ព្រះអង្គ ។

នៅពេលដែលព្រះអម្ចាស់យេស៊ូបង្គាប់យើងថា៖*«ខ្ញុំបានទទួលគ្រប់អំណាចទាំងនៅស្ថានបរមសុខ ទាំងនៅលើផែនដី ។ ដូច្នេះ ចូរចេញទៅនាំមនុស្សគ្រប់ជាតិសាសន៍ អោយធ្វើជាសាវ័ក ហើយធ្វើពិធីជ្រមុជទឹកអោយគេ ក្នុងព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ ។ ត្រូវបង្រៀនគេអោយប្រតិបត្តិតាមសេចក្តីទាំងប៉ុន្មាន ដែលខ្ញុំបានបង្គាប់អ្នករាល់គ្នា ។ ចូរដឹងថា ខ្ញុំនៅជាមួយអ្នករាល់គ្នាជារៀងរាល់ថ្ងៃ រហូតដល់អវសានកាលនៃពិភពលោក »* គឺព្រះអង្គប្រកាសថា ព្រះអង្គមានគ្រប់អំណាចទាំងអស់ ។

(ម៉ាថាយ ២៨:១៨-២០)



៣- ប្រកាន់យកថ្ងៃអាទិត្យទុកជាថ្ងៃថ្វាយបង្គំ :

---

សូមអាន រ៉ូម ១៤:៥ និង កិច្ចការ ២០:៧ ដើម្បីអាចដឹងថា សកម្មភាពនេះជាអ្វី ។

៤- ហាមឃាត់មិនអោយលេងភ្លេង ក្នុងកម្មវិធីថ្វាយបង្គំ :

---

សូមអាន ទំនុកតម្កើង ១៥០ ដើម្បីអាចដឹងថា សកម្មភាពនេះជាអ្វី ។

៥- ការបង្ហាត់បង្រៀនពួកអ្នកដឹកនាំរបស់ក្រុមជំនុំ :

---

សូមអាន ២ ធីម៉ូថេ ២:២ និង ទីតុស ១:៥ ដើម្បីអាចដឹងថា សកម្មភាពនេះជាអ្វី ។

© Project WorldReach © SEAN

## ការប្រឡង (សំនួរសង្ខេបមេរៀន)

សូមសរសេរក្បែរសកម្មភាពនិមួយៗ ដែលមានរៀបរាប់ខាងក្រោមនេះថា តើជា «សេចក្តីបង្គាប់របស់ព្រះជាម្ចាស់» «ការប្រតិបត្តិរបស់ពួកសាវក» ឬ «ទំនៀមទំលាប់របស់មនុស្ស» :

១- ការផ្សាយដំណឹងល្អថ្វាយព្រះគ្រីស្ត ដោយសារឫទ្ធានុភាពរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ :

---

សូមអាន ម៉ាថាយ ២៨:១៨-២០ និង លូកា ២៤: ៤៦-៤៩ ដើម្បីអាចដឹងថា សកម្មភាពនេះជាអ្វី ។

២- ប្រកាន់យកថ្ងៃសៅរ៍ទុកជាថ្ងៃឈប់សំរាក :

---

ចំលើយ : ទំនៀមទំលាប់របស់មនុស្ស (ជាសេចក្តីបង្គាប់សំរាប់តែសម័យកាលសម្ពន្ធមេត្រីចាស់តែប៉ុណ្ណោះ កូឡុស ២:១៣-១៧) ។ មិនមែនជាសេចក្តីបង្គាប់របស់សម្ពន្ធមេត្រីថ្មីទេ ។



## អំណាច

អំណាចសំរាប់ណែនាំ និង គ្រប់គ្រងជីវិតរបស់ក្រុមជំនុំរបស់ព្រះ-យេស៊ូគ្រីស្ត ទាំងខាងផ្នែកគោលជំនឿ ទាំងខាងការអនុវត្ត និងទាំងខាងជីវិតរស់នៅប្រចាំថ្ងៃ មានបីកំរិត ។

### អំណាចកំរិតទីមួយ

សេចក្តីបង្គាប់របស់ព្រះជាម្ចាស់ នៅក្នុងសម្ពន្ធមេត្រីថ្មី ជាអំណាចខ្ពស់បំផុត : យើងត្រូវប្រតិបត្តិតាមសេចក្តីបង្គាប់ទាំងនោះ ខានមិនបាន (ម៉ាថាយ ២៨:១៨-២០) ។

### អំណាចកំរិតទីពីរ

ការប្រតិបត្តិរបស់ពួកសាវក : យើងអាចធ្វើតាមគំរូរបស់សាវកបាន (អ្វីៗដែលពួកសាវកបានធ្វើ គ្មានចែងទុកជាសេចក្តីបង្គាប់ទេ) ។

### អំណាចកំរិតទីបី

ទំនៀមទំលាប់ និង ក្បួនច្បាប់របស់មនុស្ស (ទំនៀមទំលាប់ទាំងឡាយ ដែលគ្មានចែងទុកក្នុងសម្ពន្ធមេត្រីថ្មី) : យើងប្រតិបត្តិតាម ឬ មិនប្រតិបត្តិតាម យោងទៅតាមសេចក្តីទាំងនោះមានប្រយោជន៍ ឬ គ្មានប្រយោជន៍ ។

សូមសរសេរអំណាចទាំងបីកិរិត :

១- សេចក្តី _____របស់ព្រះជាម្ចាស់ (អំណាចខ្ពស់បំផុត) ។

២- ការប្រ _____របស់ពួកសាវ័ក ។

៣- ទំនៀម _____របស់មនុស្ស ។

ការដែលចេះមើលស្គាល់ថា សេចក្តីណាជាសេចក្តីបង្គាប់របស់ព្រះជាម្ចាស់ នៅក្នុងសម្ពន្ធមេត្រីថ្មី សេចក្តីណាជាការប្រតិបត្តិរបស់ពួកសាវ័ក និង សេចក្តីណាជាទំនៀមទំលាប់របស់មនុស្ស នាំឱ្យអាចដោះស្រាយបញ្ហាជាច្រើន ដែលកើតមានរវាងពួកអ្នកជឿ និងរវាងក្រុមជំនុំទាំងឡាយ ហើយជួយយើងអោយចេះប្រតិបត្តិតាមព្រះគ្រីស្ត ។ ការបែកបាក់គ្នា ស្ទើរតែទាំងអស់ សុទ្ធតែបណ្តាលមកពីអ្នកជឿម្នាក់មានបំណងចង់គាបសង្កត់លើអ្នកឯទៀត ។ អ្នកនោះប្រកាន់យកការប្រតិបត្តិណាមួយរបស់ពួកសាវ័ក ឬ ទំនៀមទំលាប់ណាមួយរបស់មនុស្ស ទុកជាសេចក្តីបង្គាប់តាមផ្លូវច្បាប់ ។ ការធ្វើដូចនេះ នាំអោយមានការបែកបាក់គ្នា ។

សូមគូសសញ្ញា «✓ »នេះ ដើម្បីបង្ហាញថា ឃ្លាណាមួយ នៅទំព័របន្ទាប់ ត្រូវនឹងអំណាចកិរិតណាមួយ :



ចំលើយ : វគ្គគម្ពីរនេះប្រាប់ពួកអ្នកជឿឱ្យចៀសវាង កុំស្រឡាញ់លោកីយ៍ ។ ព្រោះមនុស្សមិនអាចស្រឡាញ់ព្រះជាម្ចាស់ផង ស្រឡាញ់លោកីយ៍ផងបានទេ ។ លោកីយ៍ គឺជាបំណងខ្លាំងក្លារបស់មនុស្សមានបាប កាមគុណថោកទាបតាមរយៈភ្នែក និង ការអួតអាងពីទ្រព្យរបស់ និង ស្នាដៃរបស់មនុស្សម្នាក់ ។ លោកីយ៍នឹងកន្លងបាត់ទៅ ប៉ុន្តែ មាគ៌ារបស់ព្រះជាម្ចាស់ នៅស្ថិតស្ថេរជារៀងរហូត ។

តើមានការអនុវត្តអ្វីខ្លះ សំរាប់ពេលសព្វថ្ងៃនេះ ?

ចំលើយ : សព្វថ្ងៃនេះ អ្នកជឿជាច្រើនបាត់បង់ជំនឿ ដោយសារចង់បានអ្វីៗ ដែលនៅក្នុងលោកីយ៍ ដូចជាប្រាក់កាស កិត្តិនាម ឬ បុណ្យសក្តិក្នុងសង្គម ។ មនុស្សទាំងនេះអាចមានប្រាក់កាស និងទ្រព្យសម្បត្តិ ប៉ុន្តែ ពួកគេនឹងបាត់បង់ព្រលឹងនៅទីបញ្ចប់ ។ ព្រោះលោកីយ៍គ្រាន់តែបណ្តោះអាសន្នប៉ុណ្ណោះ ឯមាគ៌ារបស់ព្រះជាម្ចាស់នៅស្ថិតស្ថេរជារៀងរហូត ហើយតែងតែដឹកនាំទៅរកសេចក្តីសុខសាន្ត និង ជីវិត ។ យើងត្រូវជ្រើសរើសយកដៃគូរបស់យើង គឺយើងអាចជ្រើសរើសយកលោកីយ៍ ឬមួយយកព្រះយេស៊ូ ព្រមទាំងត្រូវដឹងថា បើយើងជ្រើសយកអ្នកណាមួយ យើងនឹងទទួលបានលទ្ធផលដូចម្តេច ។

តើមានបរិបទដូចម្តេច ? (រឿងអ្វីកើតមុន និង មានរឿងអ្វីកើតបន្ទាប់ និង ហេតុការណ៍ប្រវត្តិសាស្ត្រ) ។

ចំលើយ : លោកយ៉ូហាននិយាយនៅក្នុង ១ យ៉ូហាន ចំពូក ទី ១ ថា គាត់ប្រកាសពីអ្វីដែលគាត់បានឃើញ និង បានឮ ដើម្បីឱ្យពួកអ្នកជឿអាចមានមេត្រីភាពពិតជាមួយព្រះយេស៊ូ និង ជាមួយអ្នកជឿឯទៀត ។ គាត់រំលឹកដាស់តឿនពួកអ្នកជឿអោយចេះស្តាប់បង្គាប់ ចេះស្រឡាញ់ និង អោយដើរក្នុងពន្លឺ ។

តើតួអង្គជានរណាខ្លះ ?

ចំលើយ : សំណួរនេះមិនទាក់ទងនឹងវគ្គគម្ពីរនេះទេ ។

តើនរណានិយាយទៅកាន់នរណា ?

១ យ៉ូហាន ២:១៣-១៤ បង្ហាញថា លោកយ៉ូហាននិយាយទៅកាន់បុត្រធីតារបស់ព្រះជាម្ចាស់ គឺឪពុកៗ និង យុវជន ។ ដូច្នេះគឺគាត់រំលឹកដាស់តឿនពួកអ្នកជឿលើព្រះយេស៊ូគ្រីស្តទាំងអស់ ។

តើវគ្គគម្ពីរនេះនិយាយពីអ្វី ?



**ការកែប្រែចិត្តគំនិតពីអំពើបាប ជា :**

☐ សេចក្តីបង្គាប់ក្នុងសម្ពន្ធមេត្រីថ្មី ។

☐ គ្រាន់តែជាការប្រតិបត្តិរបស់ពួកសាវ័កប៉ុណ្ណោះ ។

☐ ទំនៀមទំលាប់របស់មនុស្ស (គ្មាននៅក្នុងព្រះគម្ពីរទេ) ។

ចំលើយ : ព្រះជាម្ចាស់បានបង្គាប់អោយយើងកែប្រែចិត្តគំនិត (ម៉ាកុស ១:១៥) ។

សេចក្តីបង្គាប់របស់ព្រះគម្ពីរ ងាយរកឃើញ និង ងាយមើលស្គាល់ ហើយមានកត់ត្រាច្បាស់លាស់ នៅក្នុងសម្ពន្ធមេត្រីថ្មី ។ ដូច្នេះយើងមិនត្រូវពឹងលើការបកស្រាយរបស់មនុស្សទេ ។ សេចក្តីបង្គាប់ទាំងនេះ សំរាប់អ្នកជឿនៅគ្រប់ក្រុមជំនុំទាំងអស់ ។

**ការតមអាហារមុនដឹងតែងតាំង ឬ ចាត់ត្រួតងារ និង ត្រីស្តូតជា :**

☐ សេចក្តីបង្គាប់របស់ព្រះជាម្ចាស់ ។

☐ ការប្រតិបត្តិរបស់ពួកសាវ័ក ។

☐ ទំនៀមទំលាប់របស់មនុស្ស ។

© Project WorldReach © SEAN

ចំលើយ : ការនេះមិនមែនព្រះជាម្ចាស់បង្គាប់អោយយើងធ្វើទេ គ្រាន់តែជាការប្រតិបត្តិរបស់ក្រុមជំនុំពួកសាវ័កប៉ុណ្ណោះ (កិច្ចការ ១៣:៣, ១៤:២៣) ។ សព្វថ្ងៃនេះ ក្រុមជំនុំខ្លះធ្វើដូចនេះ ប៉ុន្តែយើងគ្មានអំណាច បង្ខំឱ្យមនុស្សប្រតិបត្តិដូចនេះទេ ។ ការនេះគ្រាន់តែជាការប្រតិបត្តិរបស់ពួកសាវ័ក មិនមែនជាសេចក្តីបង្គាប់របស់ព្រះជាម្ចាស់ទេ ។

ការប្រតិបត្តិផ្សេងៗទៀតរបស់ពួកសាវ័ក ដែលមិនមែនជាសេចក្តីបង្គាប់ដែរនោះ មានការអធិស្ឋានដាក់ដៃលើគេ (១ ធីម៉ូថេ ៤:១៤) ការធ្វើពិធីកាច់នំប៉័ងញឹកញាប់ នៅតាមផ្ទះអ្នកជឿ (កិច្ច-ការ ២:៤៦) និង ការយកទ្រព្យសម្បត្តិ ដែលខ្លួនមានទាំងប៉ុន្មានមកដាក់រួមគ្នា (កិច្ចការ ២:៤៤-៤៥) ។ ការប្រតិបត្តិទាំងអស់នេះសុទ្ធតែល្អ ប៉ុន្តែ មិនមែនជាសេចក្តី ដែលព្រះជាម្ចាស់បង្គាប់អោយធ្វើទេ ។ យើងយកសេចក្តីបង្គាប់របស់ព្រះជាម្ចាស់ធ្វើជាមូលដ្ឋានរបស់អ្វីៗគ្រប់យ៉ាង ព្រោះសេចក្តីបង្គាប់ទាំងនេះសំខាន់ណាស់ សំរាប់អប់រំមនុស្សអោយចេះប្រតិបត្តិតាមព្រះជាម្ចាស់ ។



ឥឡូវនេះ អ្នកនឹងសិក្សា ១ យ៉ូហាន ២:១៥-១៧ ហើយសរសេរចំលើយរបស់អ្នក ចំពោះសំណួរដែលដូចខាងលើនេះ នៅលើក្រដាសមួយសន្លឹកផ្សេង ។ បន្ទាប់មក ប្រៀបធៀបចំលើយរបស់អ្នកជាមួយចំលើយដែលមានដាក់ជូនក្នុងកូនសៀវភៅនេះ ។

តើអ្នកណាជាអ្នកនិពន្ធ ?

ចំលើយ : លោកយ៉ូហាន ដែលជាសាវ័ករបស់ព្រះយេស៊ូ និងដែលបានសរសេរសៀវភៅដំណឹងល្អយ៉ូហាន និង សៀវភៅវិវរណៈផងដែរ ។

តើហេតុការណ៍នេះ កើតមាននៅឯណា ?

ចំលើយ : វគ្គនេះមិនមែននិយាយពីហេតុការណ៍មួយទេ ប៉ុន្តែជាការរំលឹកដាស់តឿនតាមរយៈសំបុត្រ ។

តើសំបុត្រនេះសរសេរនៅពេលណា ?

ចំលើយ : សំបុត្រនេះប្រហែលជាសរសេរនៅចន្លោះ គ. ស. ទី ៨៥ និង ទី ៩៥ ។

ប៉ុន្តែ មានតែម្នាក់គត់ ដែលត្រឡប់ទៅអរព្រះគុណព្រះយេស៊ូវិញ ។ ព្រះយេស៊ូមានបន្ទូលទៅគាត់ថា÷ «ជំនឿរបស់អ្នកបានសង្គ្រោះអ្នកហើយ» ។

តើមានការអនុវត្តអ្វីខ្លះ សំរាប់ពេលសព្វថ្ងៃនេះ ?

ចំលើយ : នៅពេលដែលមនុស្សនោះត្រឡប់មករកព្រះយេស៊ូវិញ ព្រះយេស៊ូមានបន្ទូលទៅគាត់ថា÷ «ជំនឿរបស់អ្នកបានសង្គ្រោះអ្នកហើយ» ប៉ុន្តែ ព្រះយេស៊ូបានប្រោសគាត់ឱ្យជាស្អាតមុននោះរួចហើយ ។ ដូចនេះ ព្រះបន្ទូលនេះចង់សំដៅទៅលើការប្រោសព្រលឹងវិញ្ញាណអោយជា ដែលជាការសង្គ្រោះពីអំពើបាប ។ មនុស្សប្រាំបួននាក់ទៀតបានជាស្អាតខាងរូបកាយ ប៉ុន្តែ ព្រលឹងពួកគេមិនទាន់ជាទេ ។ អ្នកទាំងប្រាំបួននាក់ទទួលអំណោយ តែមិនទទួលម្ចាស់អំណោយទេ ។ សព្វថ្ងៃនេះ មនុស្សជាច្រើនចង់អោយព្រះយេស៊ូជួយពួកគេអោយមានសុខភាពល្អ ជួយពួកគេឱ្យរកបានការងារធ្វើ ឬ ជួយពួកគេអោយរៀនពូកែនៅសាលា ។ ប៉ុន្តែ ពួកអ្នកទាំងនោះមិនចង់ទទួលព្រះយេស៊ូទេ ។ យើងចាំបាច់ត្រូវធ្វើដូចមនុស្សម្នាក់ ដែលត្រឡប់មកអរព្រះគុណ និង សរសើរតម្កើងព្រះយេស៊ូវិញ ។



**ការធ្វើពិធីសាសនាដើម្បីលុបលាងកំហុស ជា :**
(ដូចជាធម្មយាត្រា ការស្វះស្វែងមិដដែលៗ ឬ ឧទ្ទិសដល់ព្រលឹងពួកអ្នកស្លាប់) ។

☐ សេចក្តីបង្គាប់របស់ព្រះជាម្ចាស់ ។

☐ ការប្រតិបត្តិរបស់ពួកសាវក ។

☐ ទំនៀមទំលាប់របស់មនុស្ស ។

ចំលើយ : សកម្មភាពសាសនាដូចនេះ គ្មាននៅក្នុងព្រះគម្ពីរទេ គឺគ្រាន់តែជាទំនៀមទំលាប់ ឬ ប្រពៃណីរបស់មនុស្សប៉ុណ្ណោះ ។ ទំនៀមទំលាប់ខ្លះរបស់មនុស្សមានប្រយោជន៍ តែខ្លះទៀតនាំអោយមានគ្រោះថ្នាក់ ។

**ការធ្វើពិធីជ្រមុជទឹកអោយពួកអ្នកជឿថ្មី ជា :**

☐ សេចក្តីបង្គាប់របស់ព្រះជាម្ចាស់ ។

☐ ការប្រតិបត្តិរបស់ពួកសាវក ។

☐ ទំនៀមទំលាប់របស់មនុស្ស ។

ចំលើយ : មហាបណ្តាំដ៏ធំរបស់ព្រះគ្រីស្ត បង្គាប់អោយធ្វើពិធីជ្រមុជទឹក អោយអស់អ្នកជឿដែលបានកែប្រែចិត្តគំនិត (ម៉ាថាយ ២៨:១៨-២០) ។ នេះជាសេចក្តីបង្គាប់របស់ព្រះជាម្ចាស់ ។

**ការធ្វើពិធីជ្រមុជទឹកអោយពួកអ្នកជឿថ្មីភ្លាមៗ ជា :**

☐ សេចក្តីបង្គាប់របស់ព្រះជាម្ចាស់ ។

☐ ការប្រតិបត្តិរបស់ពួកសាវក ។

☐ ទំនៀមទំលាប់របស់មនុស្ស ។

ចំលើយ : ពួកសាវកតែងតែធ្វើពិធីជ្រមុជទឹកភ្លាមៗ (កិច្ចការ ២:៤១ ។ល។) ។ តែនេះជាការប្រតិបត្តិរបស់ពួកសាវក ដូច្នេះមិនអាចចាត់ទុកជាសេចក្តីបង្គាប់ទេ ។

**ការធ្វើពិធីជ្រមុជទឹក បន្ទាប់ពីបានសិក្សាព្រះគម្ពីរច្រើនខែ ជា :**

☐ សេចក្តីបង្គាប់របស់ព្រះជាម្ចាស់ ។

☐ ការប្រតិបត្តិរបស់ពួកសាវក ។

☐ ទំនៀមទំលាប់របស់មនុស្ស ។



ចំលើយ : ព្រះយេស៊ូបានចែកចាយសេចក្តីបង្រៀន គោលការណ៍ និង ប្រស្នាផ្សេងៗ អំពីព្រះរាជ្យរបស់ព្រះអង្គ និង មាគ៌ារបស់ព្រះអង្គ ។

តើតួអង្គជានរណាខ្លះ ?

ចំលើយ : មនុស្សឃ្លង់ដប់នាក់ និង ព្រះយេស៊ូ ។

នរណានិយាយទៅកាន់នរណា ?

ចំលើយ : ព្រះយេស៊ូមានបន្ទូលជាពិសេសបំផុត ទៅមនុស្សម្នាក់ (មនុស្សសាសន៍សាម៉ារី)ដែលត្រឡប់មកអរព្រះគុណព្រះយេស៊ូវិញ ព្រោះព្រះអង្គបានប្រោសគាត់អោយបានជាស្អាត ។ ប៉ុន្តែ ព្រះ-បន្ទូលព្រះយេស៊ូនៅក្នុងវគ្គគម្ពីរនេះ សំរាប់មនុស្សទូទៅ ។

តើវគ្គគម្ពីរនេះនិយាយពីអ្វី ?

ចំលើយ : នេះជាហេតុការណ៍ ដែលកើតមានពិតមែន ។ វគ្គគម្ពីរនេះបង្ហាញថា ព្រះជាម្ចាស់គាប់ព្រះហឫទ័យនឹងមនុស្ស ដែលត្រឡប់មកអរព្រះគុណព្រះយេស៊ូវិញ ព្រោះព្រះអង្គបានប្រោសគាត់អោយជាស្អាត ។ មនុស្សដប់នាក់បានជាស្អាត

## ការសិក្សា

សូមមើលឧទាហរណ៍អំពីការសិក្សា លូកា ១៣:១១-១៩ ។

អ្នកណាជាអ្នកនិពន្ធ ?

ចំលើយ : លោកគ្រូពេទ្យលូកា ដែលជាមិត្តរួមដំណើររបស់លោកប៉ូល ។

តើហេតុការណ៍នេះ កើតនៅឯណា ?

ចំលើយ : នៅភូមិមួយ ដែលនៅចន្លោះស្រុកសាម៉ារី និង ស្រុកកាលីឡេ ។

តើហេតុការណ៍នេះ កើតមាននៅពេលណា ?

ចំលើយ : ហេតុការណ៍នេះកើតមាននៅពេលដែលព្រះយេស៊ូឆ្លងកាត់ភូមិនេះ ដើម្បីទៅក្រុងយេរូសាឡិម ។

តើមានបរិបទដូចម្តេច ? (រឿងអ្វីកើតមុន និង មានរឿងអ្វីកើតបន្ទាប់ ព្រមទាំងហេតុការណ៍ប្រវត្តិសាស្ត្រ ។



ចំលើយ : ក្រុមជំនុំខ្លះមានទំលាប់អោយអ្នកជឿថ្មី សិក្សាព្រះគម្ពីរមួយរយៈពេលយូរសិន ទើបអោយទទួលពិធីជ្រមុជទឹក ។

**ត្រូវស្រឡាញ់ព្រះជាម្ចាស់ និង ស្រឡាញ់មនុស្សឯទៀតៗ ជាអំណាចកំរិតណា ? ។** _____

សូមអាន ម៉ាថាយ ២២:៣៤-៤០ ដើម្បីអាចដឹងថា សកម្មភាពនេះជាអ្វី ។

**ការធ្វើពិធីកាច់នំបុ័ង ជា :** _____

សូមអាន លូកា ២២:១៩ ដើម្បីអាចដឹងថា សកម្មភាពនេះជាអ្វី ។

**ការផ្សាយដំណឹងល្អរបស់ព្រះគ្រីស្ត ជា :** _____

សូមអាន ម៉ាកុស ១៦:១៥ ដើម្បីអាចដឹងថា សកម្មភាពនេះជាអ្វី ។

**ត្រូវអធិស្ឋាន ជា :** _____

សូមអាន លូកា ២១:៣៦ ដើម្បីអាចដឹងថា សកម្មភាពនេះជាអ្វី ។

**ត្រូវស្រឡាញ់ខ្មាំងសត្រូវរបស់ខ្លួន ជា :** _____

សូមអាន ម៉ាថាយ ៥:៤៤ ដើម្បីអាចដឹងថា សកម្មភាពនេះជាអ្វី ។

**ធ្វើកាយវិការ ដោយយកម្រាមដៃចុចចំកណ្តាលថ្ងាស រួចទាញ តម្រង់ មកចំបេះដូង ហើយទាញទៅឆ្វេង និង ស្តាំជាសញ្ញា ឈើឆ្កាង ជា :** _____

**ដុតទៀនឧទ្ទិសដល់ព្រលឹងពួកអ្នកស្លាប់ ជា :**

_____

**ពាក់អាវធំចងក្រវាត់ក ពេលឡើងអធិប្បាយ ជា :**

_____

ចំលើយ : ការធ្វើសញ្ញាឈើឆ្កាង ការដុតទៀនឧទ្ទិសដល់ព្រលឹងពួកអ្នកស្លាប់ និង ការស្លៀកពាក់យ៉ាងពិសេស ជាទំនៀមទំលាប់របស់មនុស្ស មិនមែនជាសេចក្តីបង្គាប់ដែលមានចែងនៅក្នុងព្រះ-គម្ពីរទេ ។

សេចក្តីបង្គាប់ដែលមកពីព្រះជាម្ចាស់ មានគ្រប់អំណាចទាំងអស់ ព្រោះជាសេចក្តី ដែលព្រះជាម្ចាស់ដ៏ធំខ្ពស់បំផុតបានបង្គាប់ មិនមែនយើងទេ ។ យើងប្រតិបត្តិតាមសេចក្តីបង្គាប់ទាំងនេះ ដោយសារសេចក្តីស្រឡាញ់ មិនមែនដោយសារតែចង់សន្សំកុសលផលបុណ្យ តាមក្រិត្យវិន័យទេ ។ អ្នកខ្លះខំកាន់ក្រិត្យវិន័យយ៉ាងហ្មត់ចត់ និង បង្កើតបញ្ញត្តិខ្លួនឯង ដែលមិនមែនជាក្រិត្យវិន័យ



ឧទាហរណ៍ : សូមអាន ម៉ាថាយ ៣:៣ ។ អ្នកអាចឃើញថា នៅក្បែរពាក្យ «ព្រះអង្គ» មានតួអក្សរ «ង» តូចមួយ ។ អក្សរ «ង» នៅចុងទំព័រខាងក្រោមនោះ (នៅក្រោមអត្ថបទ) បង្ហាញពីខព្រះគម្ពីរយោង គឺអេសាយ ៤០:៣ ដែលទាក់ទងនឹង ម៉ាថាយ ៣:៣ ។




បានន័យថា អេសាយ ៤០:៣ មានប្រធានបទទាក់ទងនឹង ម៉ាថាយ ៣:៣ ។ សូមអាន អេសាយ ៤០:៣ ដើម្បីបញ្ជាក់សេចក្តីនេះ ។

© Project WorldReach © SEAN






របស់ព្រះជាម្ចាស់ទេ ដើម្បីទាមទារឱ្យព្រះជាម្ចាស់ប្រណីសន្តោសដល់គេ ។ បើយើងស្រឡាញ់ព្រះគ្រីស្ត យើងពិតជាកាន់តាមវិន័យរបស់ព្រះគ្រីស្ត (យ៉ូហាន ១៤:១៥, ១ កូរិនថូស ១៣:១) ។

តើអ្នកណាជាអ្នកបង្គាប់យើង ?

☐ គ្រូគង្វាល ។

☐ ព្រះជាម្ចាស់ ។

ចំលើយ : មានតែព្រះជាម្ចាស់ទេ ដែលមានអំណាចបង្គាប់ដល់ក្រុមជំនុំរបស់ព្រះអង្គ ។ គ្រូគង្វាលដឹកនាំក្រុមជំនុំដោយសារអំណាចរបស់ព្រះគ្រីស្ត ប៉ុន្តែ គ្រូគង្វាលគ្មានអំណាចបង្កើតក្រិត្យវិន័យអ្វីផ្សេង ក្រៅពីក្រិត្យវិន័យដែលមានចែងក្នុងព្រះគម្ពីរទេ ។

ព្រះជាម្ចាស់បណ្តាលឱ្យពួកសាវ័ក សរសេរសេចក្តីបង្គាប់ផ្សេងៗទៀត ក្នុងសំបុត្ររបស់ពួកសាវ័ក សំរាប់ក្រុមជំនុំទាំងឡាយ ។ សេចក្តីបង្គាប់ដែលពួកសាវ័កសរសេរទាំងនេះ មានអំណាចដូចសេចក្តីបង្គាប់របស់ព្រះយេស៊ូដែរ ពីព្រោះជាសេចក្តីបង្គាប់ដែលព្រះវិញ្ញាណដ៏វិសុទ្ធបណ្តាលអោយពួកគេសរសេរ (២ ធីម៉ូថេ ៣:១៦) ។

ចំពោះការប្រតិបត្តិរបស់ពួកសាវ័កវិញ មិនមែនត្រូវគោរពតាមដាច់ខាតគ្រប់ពេលនោះទេ គឺគួរធ្វើតាម តម្រូវទៅតាមកាលៈទេសៈ ។

**សេចក្តីបង្គាប់របស់ព្រះគ្រីស្ត ជា :**

☐ សេចក្តីដែលយើងត្រូវតែប្រតិបត្តិតាម ។

☐ សេចក្តីមិនសូវសំខាន់ ដែលយើងមិនបាច់ប្រតិបត្តិតាម ។

ចំលើយ : យើងត្រូវយកចិត្តទុកដាក់បំពេញតាមសេចក្តីបង្គាប់ទាំងនេះអោយទាន់ពេល ។ សូមកុំប្រហែសក្នុងការប្រតិបត្តិតាមព្រះជាម្ចាស់អោយសោះ (យ៉ូហាន ១៤:២១) ។

**ការប្រតិបត្តិរបស់ពួកសាវ័ក យើង :**

(ដូចជាការជួបប្រជុំនៅតាមផ្ទះរបស់ពួកអ្នកជឿ : កិច្ចការ ២:៤៦) ។

☐ ត្រូវតែធ្វើតាម ដោយខានមិនបាន ។

☐ ត្រូវហាមឃាត់ ។

☐ គួរធ្វើតាម បើសិនជាមានប្រយោជន៍ ។



១- តើអ្នកណាជាអ្នកនិពន្ធ ?

២- តើហេតុការណ៍នេះ កើតឡើងនៅឯណា ?

៣- តើហេតុការណ៍នោះ កើតមាននៅពេលណា ?

៤- តើមានរឿងអ្វីកើតមុន និង មានរឿងអ្វីកើតបន្ទាប់ (តើមានបរិបទដូចម្តេច) ?

៥- តើតួអង្គជានរណាខ្លះ ?

៦- តើនរណានិយាយទៅកាន់នរណា ?

៧- តើវគ្គគម្ពីរនេះនិយាយអំពីអ្វី ? (ពិនិត្យមើលចំណុចនិមួយៗ អោយបានល្អិតល្អន់ តើជា « ប្រស្នា » « សេចក្តីបង្គាប់ » « គំរូសំរាប់ធ្វើតាម » « ទំនៀមទំលាប់ ដែលជួយបំភ្លឺអំពីបរិបទប្រវត្តិសាស្ត្រ មានន័យថា សេចក្តីថ្លែងដែលទាក់ទងនឹងប្រវត្តិសាស្ត្រ » « ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ »។ល។) ។

៨- តើមានការអនុវត្តអ្វីខ្លះ សំរាប់ពេលសព្វថ្ងៃនេះ ? ។

ជំនួយដ៏សំខាន់សំរាប់បកស្រាយវគ្គគម្ពីរ គឺរកអោយឃើញវគ្គគម្ពីរផ្សេងៗទៀត ដែលទាក់ទងនឹងចំណុចសំខាន់ៗរបស់វគ្គគម្ពីរនោះ ។ (ជួនកាលនៅក្នុងព្រះគម្ពីរមានប្រាប់ពីខគម្ពីរយោងទាំងនោះ) ។

© Project WorldReach © SEAN

## របៀបអានព្រះគម្ពីរ

ដើម្បីអាចយល់វគ្គព្រះគម្ពីរមួយអោយបានច្បាស់លាស់ យើងត្រូវសិក្សាអំពីសេចក្តីដែលវគ្គនោះចែងប្រាប់ដោយហ្មត់ចត់ មិនមែនយល់តាមគំនិតយើងទេ ។ យើងមិនត្រូវបញ្ចេញគំនិតខ្លួនឯងទេ តែត្រូវគិតគូរ ស្របទៅតាមសេចក្តីដែលវគ្គគម្ពីរនោះចែង ។

នៅក្នុងការសិក្សាព្រះគម្ពីរ យើងអាចទាញយកសេចក្តីសន្និដ្ឋាន ពី :

☐ មតិយោបល់របស់យើង ។

☐ ការពិនិត្យមើល និង ការពិចារណា ។

ចំលើយ : ពេលយើងពិចារណាអំពីចំណុចលំអិតរបស់វគ្គព្រះគម្ពីរមួយ យើងនឹងយល់អត្ថន័យរបស់វគ្គព្រះគម្ពីរនោះ កាន់តែច្បាស់ ។ យើងមិនត្រូវអធិប្បាយព្រះបន្ទូលតាមតែការយល់ឃើញរបស់យើងផ្ទាល់ទេ តែតាមសេចក្តីចែង និង អត្ថន័យរបស់អត្ថបទនោះ ។

ដើម្បីអាចយល់វគ្គព្រះគម្ពីរមួយច្បាស់លាស់ យើងត្រូវរកចំណុចសំខាន់ៗជាច្រើន :



ចំលើយ : យើងគ្មានអំណាចបង្ខំមនុស្សអោយធ្វើតាមការប្រតិបត្តិរបស់ពួកសាវ័កទេ ព្រោះមិនមែនជាសេចក្តីបង្គាប់របស់ព្រះជាម្ចាស់ ។ ប៉ុន្តែ យើងក៏មិនគួរហាមឃាត់មិនអោយធ្វើតាមអ្វីៗដែលព្រះជាម្ចាស់បានចែងទុកជាគំរូនៅក្នុងព្រះគម្ពីរដែរ ។

**ទំនៀមទំលាប់របស់មនុស្ស :**

☐ យើងត្រូវតែធ្វើតាម ដោយខានមិនបាន ។

☐ យើងគួរទាមទារអោយមនុស្សធ្វើតាម ។

☐ យើងហាមឃាត់មិនអោយមនុស្សធ្វើតាម បើសិនជាទំនៀមទំលាប់ទាំងនោះ ធ្វើឱ្យរាំងស្ទះការងាររបស់ព្រះជាម្ចាស់ ។

ចំលើយ : យើងមិនត្រូវទទួចចង់ប្រតិបត្តិតាមប្រពៃណីរបស់មនុស្សទេ ។ បើសិនជាទំនៀមទំលាប់ទាំងនោះ រំខានយើងមិនឱ្យប្រតិបត្តិតាមសេចក្តីបង្គាប់របស់ព្រះអម្ចាស់ យើងមិនគួរធ្វើតាមទំនៀមទំលាប់ទាំងនោះទេ (ម៉ាថាយ ១៥:១-៩) ។ ប្រពៃណីខ្លះរបស់មនុស្ស មានប្រយោជន៍នៅក្នុងកាល:ទេស:ខ្លះ ហើយអាចមានអំណាចខ្លះនៅក្នុងអង្គការ ស្ថាប័ន ឬ ក្រុមជំនុំ ។

© Project WorldReach © SEAN

ឧទាហរណ៍ សមាជិកក្រុមជំនុំមួយ អាចស្ម័គ្រចិត្តសំរេចធ្វើពិធីកាច់នំបុ័ងរាល់ថ្ងៃអាទិត្យ នៅម៉ោង ៩ ព្រឹក ។ ការជួបជុំធ្វើពិធីកាច់នំបុ័ង នៅម៉ោងប្រាំបួនព្រឹកនេះ ក្លាយជាទំលាប់មួយ ដែលសមាជិកក្រុមជំនុំនោះស្រុះស្រួលគ្នាយកមកអនុវត្តតាមជាបន្តបន្ទាប់ ។

ប្រពៃណី ឬ ទំនៀមទំលាប់មួយ មានអំណាចក្នុងក្រុមជំនុំមួយ ដោយសារសមាជិកនៃក្រុមជំនុំនោះស្រុះស្រួលគ្នាអនុវត្តតាមទំនៀមទំលាប់នោះ ។ បើយកទំនៀមទំលាប់របស់ក្រុមជំនុំមួយទៅដាក់អោយក្រុមជំនុំឯទៀតធ្វើតាម ជាការមិនត្រឹមត្រូវទេ ។

អ្នកជឿនៃក្រុមជំនុំមួយ ត្រូវគិតគូរអំពី :

□ របៀបរបបរបស់ក្រុមជំនុំរបស់ខ្លួន ។

□ របៀបរបបរបស់ក្រុមជំនុំឯទៀត ។

ចំលើយ : យើងត្រូវវាយតម្លៃ និង ពិនិត្យពិច័យមើលទំនៀមទំលាប់របស់ក្រុមជំនុំយើងផ្ទាល់ ដើម្បីអោយដឹងថាទំនៀមទំលាប់ និងសកម្មភាពទាំងនេះត្រូវនឹងព្រះគម្ពីរ និង មានប្រយោជន៍សំរាប់ក្រុមជំនុំយើងដែរឬទេ ។ ប៉ុន្តែ យើងមិនត្រូវទិតៀនទំនៀមទំលាប់របស់ក្រុមជំនុំផ្សេងទៀតទេ ។



សេចក្តីខ្លះដែលមានចែងនៅក្នុងសម្ពន្ធមេត្រីថ្មី មិនមែនជាសេចក្តីបង្គាប់សំរាប់យើងទេ ។ ឧទាហរណ៍ : លោកប៉ូលបង្គាប់ធីម៉ូថេអោយយកអាវធំរបស់គាត់ (២ ធីម៉ូថេ ៤:១៣) ។ នេះមិនមែនជាសេចក្តីបង្គាប់ទូទៅទេ តែជាសេចក្តីដែលត្រូវសំរាប់ពេលវេលាណាមួយ ឬ កាល:ទេស:ណាមួយតែប៉ុណ្ណោះ ។

ព្រះយេស៊ូលាងជើងអោយពួកសាវ័ក ហើយបង្គាប់ពួកគេអោយធ្វើដូចព្រះអង្គដែរ ។ សេចក្តីទាំងអស់ដែលចែងក្នុងបទគម្ពីរយ៉ូហាន ១៣ បង្ហាញថា ព្រះគ្រីស្តបង្រៀនពួកគេអោយចេះបំរើដោយដាក់ខ្លួន ។ នៅសម័យកាលនោះ តាមទំនៀមទំលាប់ក្នុងសង្គម អ្នកបំរើដែលមានឋានៈទន់ទាបបំផុត ត្រូវលាងជើងជូនភ្ញៀវដែលបានធ្វើដំណើរមក ។ ព្រះយេស៊ូប្រើការលាងជើងដើម្បីបង្រៀនពីការបំរើដោយបន្ទាបខ្លួន ។ ការនេះមិនមែនមានន័យថា ព្រះយេស៊ូចង់ឱ្យយើងទាំងអស់គ្នាកាន់តាមទំនៀមទំលាប់នេះ គឺអោយយើងលាងជើងជូនភ្ញៀវនោះទេ ។ នៅតាមតំបន់របស់អ្នក ប្រហែលជាមានរបៀបផ្សេង ដែលយើងអាចបំរើមនុស្សឯទៀត ដោយដាក់ខ្លួនបាន ។

ការដែលសមាជិកក្រុមជំនុំចេះពិចារណាអំពីអំណាចទាំងបីកិរិតនេះ ជួយអោយគេចេះណែនាំក្រុមជំនុំរបស់គេ ។ តើអំណាចកិរិតណាមួយ ដែលយើងត្រូវតែប្រតិបត្តិតាមជានិច្ច ? ។ _____

តើវិន័យរបស់កិរិតណាមួយ ដែលយើងអាចបដិសេធបាន បើសិនជាវិន័យនោះ ធ្វើអោយរាំងស្ទះមិនអោយប្រតិបត្តិតាមព្រះយេស៊ូគ្រីស្ត ? ។ _____

តើអំណាចកិរិតណា ដែលយើងមិនត្រូវហាមឃាត់ ឬក៏មិនត្រូវបង្ខំអោយមនុស្សប្រតិបត្តិតាម ? ។ _____

ចំលើយ :

- យើងត្រូវប្រតិបត្តិតាមសេចក្តីបង្គាប់របស់ព្រះជាម្ចាស់ជានិច្ច ។
- យើងមិនត្រូវធ្វើតាមទំនៀមទំលាប់របស់មនុស្ស ដែលរាំងស្ទះយើងមិនអោយប្រតិបត្តិតាមព្រះគ្រីស្តឡើយ ។
- យើងមិនត្រូវហាមឃាត់ ឬ បង្ខំអោយមនុស្សធ្វើតាមទំនៀមទំលាប់របស់ពួកសាវក ដែលមិនមែនជាសេចក្តីបង្គាប់មកពីព្រះជាម្ចាស់នោះទេ ។



ក្រុមជំនុំនិមួយៗទទួលខុសត្រូវនៅចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់ អំពីការបង្កើតច្បាប់ និង ដំណើរការរបស់ខ្លួនផ្ទាល់ ស្របទៅតាមការជាក់ស្តែង នៅក្នុងតំបន់របស់ខ្លួន ។ គ្រីស្តជនមានឯកភាព ដោយសារព្រះវិញ្ញាណ មិនមែនដោយសារការប្រតិបត្តិ (របៀបធ្វើកិច្ច-ការ) ដូចគ្នានោះទេ ។



ពួកសាវ័កប្រឆាំងជាប់ជានិច្ច នឹងការបង្ខំមនុស្សអោយធ្វើតាមទំនៀមទំលាប់ ។

តើយើងត្រូវប្រកាន់យកការប្រតិបត្តិរបស់ក្រុមជំនុំមួយ នៅពេលណា និង ហាមឃាត់ នៅពេលណា ? ។

- ក្រុមជំនុំត្រូវប្រតិបត្តិតាម**សេចក្តីបង្គាប់របស់ព្រះជាម្ចាស់**
  (ឧទាហរណ៍ : « ចូរចេញទៅនាំមនុស្សគ្រប់ជាតិសាសន៍ឱ្យធ្វើជាសាវ័ក » ម៉ាថាយ ២៨:១៩-២០) ។

- ក្រុមជំនុំអាចប្រកាន់យក**ការប្រតិបត្តិរបស់ពួកសាវ័ក** ស្របទៅតាមស្ថានភាពរបស់ខ្លួន ។ ក្រុមជំនុំមិនត្រូវបង្ខំសមាជិកអោយប្រកាន់យកការប្រតិបត្តិរបស់ពួកសាវ័កទេ ហើយក៏មិនត្រូវហាមឃាត់មិនអោយសមាជិកប្រកាន់យកការប្រតិបត្តិរបស់ពួកសាវ័កដែរ ។
  (ឧទាហរណ៍ : « ពួកសាវ័កជ្រើសរើសបុរសប្រាំពីរនាក់ឱ្យជួយបំរើអ្នកដែលមានសេចក្តីត្រូវការ »កិច្ចការ ៦:១-៦) ។



- ក្រុមជំនុំអាចប្រកាន់យក**ទំនៀមទំលាប់ និង ប្រពៃណី** ដែលមិនផ្ទុយពីព្រះគម្ពីរ ។
  (ឧទាហរណ៍ : « ក្រុមជំនុំជួបជុំគ្នា នៅរាល់ពេលបុណ្យភ្ជុំដើម្បីអធិស្ឋានសំរាប់មាតាបិតា និង ជីដូនជីតារបស់ពួកគេដែលនៅរស់នៅឡើយ ») ។

  ក្រុមជំនុំត្រូវហាមឃាត់ប្រពៃណី ដែលផ្ទុយពីព្រះគម្ពីរ
  (ឧទាហរណ៍ : « ការអធិស្ឋានទៅនាងម៉ារី ជាមាតារបស់ព្រះយេស៊ូ ») ។

